**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ៤៧១ ទសក.អកក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំវេទិកាជាតិអេកូទេសចរណ៍ លើកទី៤ ឆ្នាំ២០២៥ ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅខេត្តសៀមរាប

ក្រសួងទេសចរណ៍ មានកិត្តិយសសូមជម្រាបជូនសាធារណជន សមាគមទេសចរណ៍ សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ ផ្នែកឯកជន អង្គការជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធនានាឱ្យបានជ្រាបថា ក្រសួងទេសចរណ៍ សហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ និងក្រសួង ស្ថាប័នពាក់ព័ន្ធ នឹងរៀបចំ **«វេទិកាជាតិអេកូទេសចរណ៍លើកទី៤»** ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅសណ្ឋាគារសុខាសៀមរាប ខេត្តសៀមរាប។

វេទិកាជាតិអេកូទេសចរណ៍នេះ ជាព្រឹត្តិការណ៍ប្រចាំឆ្នាំដ៏ធំមួយសម្រាប់វិស័យអេកូទេសចរណ៍ និងទេសចរណ៍សហគមន៍ ដែលនឹងមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ទាំងផ្នែកសាធារណៈ ឯកជន អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍ ជាពិសេសសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍នៅទូទាំងប្រទេស។ វេទិកាប្រចាំឆ្នាំនេះ នឹងបើកឱកាសក្នុងការបង្ហាញអំពីលទ្ធផលការងារ ពាក់ព័ន្ធនឹងសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ការលើកឡើងនូវបញ្ហាប្រឈម និងការពិភាក្សាដាក់ចេញជាជម្រើសដំណោះស្រាយ និងយុទ្ធសាស្ត្រនានា ក្នុងស្មារតីចែករំលែក ចូលរួម និងទទួលខុសត្រូវទាំងអស់គ្នាលើការងារអេកូទេសចរណ៍ និងសហគមន៍ទេសចរណ៍។ ព្រមជាមួយគ្នានេះ អង្គវេទិកាក៏នឹងមានការរៀបចំពិព័រណ៍សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ភ្ជាប់ជាមួយផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងទេសចរណ៍ សូមអំពាវនាវដល់សាធារណជន សមាគមទេសចរណ៍ សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ អង្គការជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលមានចំណាប់អារម្មណ៍ចូលរួម ឬមានបំណងចែករំលែកនូវលទ្ធផលការងារ និងលទ្ធផលនៃការស្រាវជ្រាវនានា មេត្តាជ្រាប និងចូលរួមឱ្យបានច្រើនកុះករ។

សម្រាប់ព័ត៌មានលម្អិតនៃការចូលរួម សូមទំនាក់ទំនងក្រុមការងារបច្ចេកទេស៖

- លោក ខៅ កុសល លេខទំនាក់ទំនង៖ ០១០ ៥០៩ ៨១៨
- លោកស្រី ស៊ីង ស្រីលក្ខណ៍ លេខទំនាក់ទំនង៖ ០៧០ ៤៦៦ ៣៧០។

ថ្ងៃច័ន្ទ ១២រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៥

ក្រសួងទេសចរណ៍